លោកប្រធាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព

ខ្ញុំមានកិត្តិយសសូមធ្វើបទ បង្ហាញនូវរបាយការណ៍ដំបូងរបស់ខ្ញុំ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ខ្ញុំសូមកោតសរសើរដល់ក្រុម ប្រឹក្សាក្នុងការជ្រើសរើសបន្តអាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា រយៈពេលពីរឆ្នាំទៀត ក្នុងសេចក្តីសម្រេចលេខ ៣០/២៣។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការគាំទ្រដ៏ស្មោះស្ម័គ្ររបស់ខ្លួនដល់ការងាររបស់ខ្ញុំ ទាំងការអញ្ជើញភ្លាមៗដើម្បីធ្វើទស្សនកិច្ចជាផ្លូវការ និងការរៀបចំនូវកិច្ចប្រជុំក្នុងអំឡុងពេលទស្សនកិច្ច ព្រមទាំងឆន្ទៈរបស់ខ្លួនក្នុងការរក្សាទំនាក់ទំនងជាមួយខ្ញុំនៅចន្លោះពេលបេសកកម្មនោះ។ របាយការណ៍របស់ខ្ញុំស្តីពីស្ថានភាពសិទ្ធិមនុស្ស កាលពីឆ្នាំមុន គឺអាចរកបានតាមលេខ A/HRC/33/62។ ខ្ញុំក៏ចាប់អារម្មណ៍ផងដែរនូវការពន្យល់របស់រដ្ឋាភិបាលនៅក្នុង GDoc ជាពិសេស ពាក់ព័ន្ធនឹងរបាំងវប្បធម៌ក្នុងការកំហិតនូវការឃុំខ្លួនបណ្តោះអាសន្ន។ ដើម្បីអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ អ.ស.ប របាយការណ៍របស់ខ្ញុំនេះ ត្រូវបានសរសេរ និងដាក់បញ្ជូនទៅ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស នៅខែឧសភា (ព័ត៌មានបន្ថែមដែលដាក់បញ្ជូនយឺតយ៉ាវ គឺ ដោយសារតែការពន្យារពេលផ្ទៃក្នុងដោយអង្គភាពដំណើរការឯកសារ)។ នៅក្នុងសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នេះ ខ្ញុំមានបំណងជាចម្បងដើម្បីធ្វើបច្ចុប្បន្នភាពដល់ក្រុមប្រឹក្សា លើដំណើរវិវឌ្ឍន៍នាពេលថ្មីៗនេះ។

ជាបឋម មានវឌ្ឍនភាពលើផ្នែកមួយចំនួន.....

បន្ទាប់ពីមានការផ្លាស់ប្តូរលើការងារទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយចំនួនធំ ក្នុងជួររាជរដ្ឋាភិបាលកម្ពុជា។ ឯកឧត្តមរដ្ឋមន្ត្រីថ្មីនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានសន្យាថានឹងបង្កើនល្បឿនអត្រានៃការផ្តល់ជូននូវប័ណ្ណកម្មសិទ្ធិដីសមូហភាព ហើយមកទល់ពេលបច្ចុប្បន្ននេះ ការផ្តល់ជូនប័ណ្ណកម្មសិទ្ធិដីសមូហភាពសរុបមានចំនួន ១៤ ហើយ (កថាខ័ណ្ឌ ១៦ នៃរបាយការណ៍របស់ខ្ញុំ)។

ចំពោះសិទ្ធិស្ត្រីវិញ មានផែនការក្នុងការធ្វើសេចក្តីព្រាងច្បាប់មួយស្តីពីការពពោះជំនួស ដែលច្បាប់នេះគួរតែអាចជួយការពារស្ត្រីកម្ពុជាពីឈ្មួញកណ្តាលពពោះជំនួសដោយទុច្ចរិត និងការប្រឆាំងនឹងការជួញដូរមនុស្សដែលកើតចេញពីការករណីបែបនេះ។

ដំណើរវិវឌ្ឍន៍លើការពង្រឹងនូវការរៀបចំតុលាការគឺកំពុងតែបន្ត ហើយអាចកសាងមូលដ្ឋានគ្រឹះបន្ថែមទៀតសម្រាប់ប្រព័ន្ធតុលាការមិនលំអៀង ដោយមានសភាជំនាញ ប្រាក់បៀវត្សរ៍សមរម្យ និងក្រមសីលធម៌។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កំពុងបន្តវឌ្ឍនភាពលើការចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតឆ្នាំ ២០១៧ និងឆ្នាំ ២០១៨។

ពាក់ព័ន្ធនឹងបណ្តឹងនានាដែលត្រូវបានរាយការណ៍៖

១) លិខិតអំពាវនាវជាបន្ទាន់ និងលិខិតអះអាងជាបន្តបន្ទាប់ (KHM 5/2015 និង KHM 2/2016) លើការឃុំខ្លួនតាមទំនើងចិត្តលើអ្នកការពារសិទ្ធិមនុស្ស ដែលធ្វើការជាមួយអង្គការមាតាធម្មជាតិ។ បុគ្គលិកចំនួនបីរូបនៃអង្គការនេះ ត្រូវបានផ្តន្ទាទោសកាលពីខែកក្កដា ឆ្នាំ ២០១៦ ហើយពួកគេត្រូវបានដោះលែង បន្ទាប់ពីការឃុំខ្លួនបណ្តោះអាសន្នជិតមួយឆ្នាំ។

២) លោក នី ចរិយា (អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត) និងជាកម្មវត្ថុនៃលិខិតអះអាងមួយកាលខែសីហា ឆ្នាំ ២០១៥ (KHM 3/2015) ត្រូវបានផ្តន្ទាទោសកាលពីសប្តាហ៍មុន ហើយបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលប្រាំមួយខែ និងពិន័យជាប្រាក់។ គួរកត់សម្គាល់ថា លោកត្រូវបានចាប់ឃុំខ្លួនចាប់ តាំងពីខែឧសភាមកម្ល៉េះ ពាក់ព័ន្ធនឹងបទចោទប្រកាន់ដាច់ដោយឡែកមួយក្នុងចំណោមបទចោទ ប្រកាន់នានា (ដែលជាកម្មវត្ថុនៃលិខិតអំពាវនាវ ជាបន្ទាន់កាលពីខែឧសភា)។ សារៈសំខាន់នៃសិទ្ធិទទួលបានការពារសមរម្យគ្រប់គ្រាន់ និងការសន្មតជាមុនថាគ្មានទោសសម្រាប់ លោក នី ចរិយា គឺជាបញ្ហាធ្ងន់ធ្ងរយ៉ាងពិសេស ដោយសារថា លោកត្រូវបានគេឃុំខ្លួនជាច្រើនខែរហូតដល់ការជំនុំជម្រះ។

៣) លិខិតអំពាវនាវជាបន្ទាន់ KHM 3/2016 កាលពីខែឧសភា លើការចាប់ខ្លួន និងការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សមួយចំនួនដែលធ្វើការជាមួយនឹងសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ដែលគេស្គាល់ថាជា សមាគមអាដហុក)។ បុគ្គលទាំងអស់នេះ នៅតែបន្តជាប់ឃុំខ្លួននៅឡើយ ដែលកំពុងរង់ចាំការជំនុំជម្រះ។ ក្រុមនេះរួមមាន លោក នី ចរិយា។ បទឧក្រិដ្ឋដែលចោទប្រកាន់លើពួកគេ នៅតែលេចឡើងដោយផ្អែកលើការងារ ស្របច្បាប់ក្នុងនាមជាអ្នកការពារសិទ្ធិមនុស្ស។ បទចោទប្រកាន់គួរតែមានភស្តុតាងបញ្ជាក់ ឬបុគ្គល ទាំងនេះគួរតែត្រូវបានដោះលែងជាបន្ទាន់។

កាលពីឆ្នាំមុន ខ្ញុំបានទទួលញត្តិមួយចំនួនដែលបានដាក់បញ្ជូនមកខ្ញុំ ក្នុង អំឡុងពេលបំពេញបេសកកម្មរបស់ខ្ញុំ និងក្រៅពីដំណើរទស្សនកិច្ច។ ញត្តិភាគច្រើនពាក់ព័ន្ធនឹងបញ្ហាដីធ្លី៖ មានបញ្ហាជាច្រើនកើតឡើងយូរមកហើយ ហើយក្រុមប្រឹក្សាក៏បានដឹងបញ្ហាទាំងនោះច្បាស់ដែរ។ ខ្ញុំទើបតែបានទទួលសំណៅបកប្រែមួយ ហើយនឹងអាចចាប់ផ្តើមធ្វើការងារ លើបញ្ហាមួយចំនួន។ នៅត្រង់ចំណុចនេះ ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិកជាតិនៃការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដែលបានបំពេញការងារដ៏ល្អ។ ចំណេះដឹង វិជ្ជាជីវៈ និងការលះបង់របស់ពួកគេដើម្បីកែលម្អស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា គឺហាក់ដូចជាគ្មានដែន កំណត់ទេ បើទោះបីជាមានការគំរាមកំហែងរកចាប់ខ្លួនបុគ្គលិកមួយរូបទាក់ទងនឹងការបំពេញការងាររបស់ លោកក្នុងនាមជាមន្ត្រីរបស់ការិយាល័យ OHCHR ក៏ដោយ។

ដោយកត់សម្គាល់ថា អនុស្សារណៈនៃការយោគយល់ រវាងរាជរដ្ឋាភិបាល និងការិយាល័យ OHCHR នៅតែមិនទាន់បានបន្តនៅឡើយនោះ ខ្ញុំសូមស្នើថា ភាគីទាំងពីរគួរធ្វើការងារបន្តអនុស្សារណៈនៃការយោគយល់នេះឲ្យបានឆាប់រហ័យ។

លោកប្រធាន ឯកឧត្តម លោកជំទាវ ជាទីគោរព

ម្ភៃប្រាំឆ្នាំកន្លងមក សមាជិកជាច្រើនរូបនៃក្រុមប្រឹក្សានេះ និងអង្គការសហប្រជាជាតិ បានចូលរួមក្នុងកិច្ចពិភាក្សានានាដែលបាននាំឲ្យមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ២៣ ខែតុលា ឆ្នាំ ១៩៩១។ ក្របខ័ណ្ឌនេះ សម្រាប់ដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា ដែលនេះជួយនាំមកនូវសន្តិភាពដល់កម្ពុជា និងបានកសាងនូវមូលដ្ឋានគ្រឹះសម្រាប់ប្រទេសកម្ពុជា ដោយផ្អែកលើច្បាប់រដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល ដែលរួមបញ្ចូលនូវ "វិធានការពិសេសៗដើម្បីធានាការការពារសិទ្ធិមនុស្សនានា (ឧបសម្ព័ន្ធ ៥ កថាខ័ណ្ឌទី ២)។ អាចមានមន្ទិលសង្ស័យបន្តិចបន្តួចដែលថា ដោយមានជំនួយពីសហគមន៍អន្តរជាតិ និង សហគមន៍នៃអង្គការមិនមែនរដ្ឋាភិបាលដែលរឹងមាំ និងរស់រវើក ប្រជាជនកម្ពុជា និងរដ្ឋាភិបាលដែលជាប់ឆ្នោតរបស់ពួកគេ បានផ្លាស់ប្តូរប្រទេសមួយនេះ។ ទោះជាយ៉ាងនេះក៏ដោយ អត្ថប្រយោជន៍ពីវឌ្ឍនភាពនេះ មិនទទួលបានដោយលក្ខណៈស្មើភាពគ្នាក្នុងចំណោមប្រជាពលរដ្ឋទាំងមូលនោះទេ។ ជាងនេះទៅទៀត ការ ការពារសិទ្ធិមនុស្សដែលមានចែងនៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ត្រូវបានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ។ មាត្រា ៣១ ចែងថា៖

> *"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ... ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិចូលដូចគ្នាទាំងអស់ ... ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"*

រដ្ឋធម្មនុញ្ញ និងច្បាប់មួយចំនួនធំ អះអាងសំដៅការពារសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងនោះ

ដែលរដ្ឋាភិបាលកម្ពុជាបានទទួលយកដោយស្ម័គ្រចិត្ត។ ដូចជាត្រឹមត្រូវចំពោះករណីនេះ ទីបំផុត ច្បាប់ទាំងឡាយត្រូវបានអនុវត្ត និងពង្រឹងដោយតុលាការ។ នៅប្រទេសកម្ពុជា មានភ័ស្តុតាងច្រើនឡើងៗដែលបង្ហាញថា ការអនុវត្តច្បាប់ទាំងនោះដោយតុលាការ ឆ្លុះបញ្ចាំងឲ្យឃើញមន្ទិលសង្ស័យលើឯករាជភាព របស់ប្រព័ន្ធតុលាការ ដោយហេតុថា ច្បាប់នេះកំពុងត្រូវបានអនុវត្តក្នុងរបៀបមួយដែលដាក់ទោសទណ្ឌយ៉ាងធ្ងន់ធ្ងរចំពោះមតិ និងសេចក្តីអធិប្បាយប្រឆាំងខាងនយោបាយ។ ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតនូវរដ្ឋធម្មនុញ្ញ "*ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ ដោយឥតប្រកាន់និន្នាការនយោបាយឡើយ*"។ ខ្ញុំទទួលយកទាំងស្រុងថា ប្រព័ន្ធតុលាការឯករាជ្យមួយ មិនត្រូវមានការសម្រុបសម្រួលដោយអង្គនីតិប្រតិបត្តិ ឬអង្គនីតិ

បញ្ញត្តិឡើយ។ ជាការពិតណាស់ នោះគឺជាលក្ខខណ្ឌតម្រូវស្នូលមួយនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយ ស្ថាប័នមួយនេះដែលកំពុងតែមានរឿងក្តីដែលមិនទាន់ចាត់ការរួច និងការផ្តន្ទាទោសជាច្រើន ទំនងជាមានភាពមិនសមាមាត្រដែលធ្វើឲ្យប៉ះពាល់ដល់គណបក្សប្រឆាំង។ បើទោះបីជា តុលាការកម្ពុជាត្រូវតែដើរតួជាស្ថាប័នឯករាជ្យ ដូចដែលរដ្ឋាភិបាលបានបញ្ជាក់នោះ ដូច្នេះការពន្យល់ដែលអាចបន្តទៅបានតែមួយគត់គឺថា ច្បាប់អាចត្រូវបានអនុវត្តក្នុងរបៀបមួយ ដែលរឹតត្បិតសិទ្ធិមនុស្សសំខាន់ៗ ដែលការពារដោយរដ្ឋធម្មនុញ្ញកម្ពុជា។ ដូច្នេះ ច្បាប់ទាំងនេះត្រូវតែបានធ្វើការត្រួតពិនិត្យឡើងវិញឲ្យបានហ្មត់ចត់ និងកែលម្អជាការចាំបាច់។ នេះប្រហែលជាបញ្ហាពិសេសមួយនៅក្នុងប្រទេសកម្ពុជា ដោយសារតែច្បាប់ជាច្រើនរបស់ខ្លួនត្រូវបានអនុម័តយ៉ាងឆាប់រហ័ស ដោយយកពីទំនៀមទម្លាប់ច្បាប់បរទេសក្នុងការបង្កើតក្របខណ្ឌច្បាប់មួយ។ ក៏មានតម្រូវការបន្ទាន់មួយទៀតផងដែរ ក្នុងការត្រួតពិនិត្យឡើងវិញនូវជាតុផ្សំនានានៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធាននៃភស្តុតាង ដែលឈានដល់ការផ្តន្ទាទោសមួយចំនួនដែលខ្វះនូវបទដ្ឋានទូទៅនៃការបង្ហាញភស្តុតាង ឧទាហរណ៍ ការផ្តន្ទាទោសអំពីការក្លែងបន្លំដោយមិនមានការបង្ហាញភស្តុតាងថាឯកសារពិតត្រូវបានក្លែងបន្លំ/កែប្រែ ដោយជនជាប់ចោទ (ឧទា. រឿងក្តីលោក ហុង សុខហួរ) ការពឹងផ្អែកលើពាក្យថាលើកលែងតែបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ (មាត្រា ៨០ កថាខ័ណ្ឌទី៣ ចំពោះការដកអភ័យឯកសិទ្ធិសភា) នៅពេលមានការចាប់ខ្លួន បន្ទាប់ពីមានការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ (ឧទា. ករណីលោក កឹម សុខា ប្រធានស្តីទីនៃគណៈបក្សសង្គ្រោះជាតិ)។

ខ្ញុំក៏មានកង្វល់ផងដែរចំពោះការចោទប្រកាន់មួយចំនួនពីបទដឹកនាំ និងចូលរួមធ្វើកុបកម្ម និងការញុះញង់ វាហាក់ដូចជាថា អាជ្ញាធរកម្ពុជាគិតថា ប្រទេសនេះស្ទើរតែធ្លាក់ទៅក្នុងអន្តរាយ ជាជាង ប្រទេសមានស្ថេរភាព និងសន្តិភាព រដ្ឋាភិបាលបានចង្អុលបង្ហាញដូច្នេះ។ យុទ្ធនាការជាសាធារណៈនានា ដែលទាមទារឲ្យមានការដោះលែងជនជាប់ឃុំ និងជូនដំណឹងអំពីការប្រមូលផ្តុំជាសាធារណៈ ដើម្បីសម្តែងមតិប្រឆាំងខាងនយោបាយ ដែលបង្ហាញដោយអង្គហេតុថា មិនបង្កើតជាអំពើកុបកម្ម ការញុះញង់ ឬជាបញ្ហាប្រឈមសម្រាប់សណ្តាប់ធ្នាប់សាធារណៈទេ។ ច្បាប់ទាំងឡាយដែលបានអនុម័តនាពេលថ្មីៗនេះ ទាមទារឲ្យមានអព្យាក្រឹតភាពនយោបាយរបស់សហជីពនិងអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែ ក្នុងការអនុវត្តច្បាប់ទាំងនោះ សូម្បីតែការជួបជុំសម្រាប់គោលបំណងអប់រំនិងការបណ្តុះបណ្តាលក៏ត្រូវបានបង្ការមិនឲ្យមានដែរ។

នៅខែមិថុនា ក្នុងអំឡុងសម័យប្រជុំខួប១០ឆ្នាំរបស់ក្រុមប្រឹក្សា មានប្រទេសជាច្រើនបានលើកឡើងអំពីកង្វល់នានាទាក់ទងនឹងលំហប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា។ បន្ថែមពីលើនេះ មានសេចក្តីថ្លែងការណ៍ជាច្រើនត្រូវបានធ្វើឡើង កាលពីដើមខែនេះ។ កង្វល់នានា ត្រូវបានលើកឡើងដោយ ឧត្តមស្នងការសិទ្ធិមនុស្ស ក៏ដូចជា ដោយរូបខ្ញុំផ្ទាល់ និងអ្នកកាន់អាណត្តិនីតិវិធីពិសេសផ្សេងទៀត។ វាមិនមានមន្ទិលទេថា ច្បាប់សំខាន់ៗមួយចំនួនកាន់តែត្រូវបានប្រើប្រាស់ដើម្បីធ្វើឲ្យរួមតូចនូវកិច្ចពិភាក្សានយោបាយ និង

គណនេយ្យភាព។ ការគោរពនីតិរដ្ឋនៅក្នុងសង្គមប្រជាធិបតេយ្យមួយ មិនមែនមានន័យថា វិធានច្បាប់មួយត្រូវបានអនុវត្តក្នុងបែបមួយដែលកំហិតសេរីភាពនៃកិច្ចពិភាក្សានយោបាយ សេរីភាពនៃការបញ្ចេញមតិ និងសម្តែងមតិនៃភាពមិនស្របគ្នានោះទេ។ ខ្ញុំបានធ្វើបញ្ជីនៃបទប្បញ្ញត្តិច្បាប់សំខាន់ៗមួយចំនួន នៅក្នុងកថាខ័ណ្ឌទី៣១ នៃរបាយការណ៍របស់ខ្ញុំ ហើយនៅក្នុងកថាខ័ណ្ឌទី៣២ ខ្ញុំបានសង្ខេបនូវសេចក្តីណែនាំសិទ្ធិមនុស្សអន្តរជាតិថ្មីៗ ទាក់ទងនឹងវិធាននៃសន្ទរកថានយោបាយ រួមទាំងសេចក្តីថ្លែងការណ៍ដែលគួរតែត្រូវបានពិចារណា ក្នុងការប្រមាថបុគ្គលសាធារណៈមួយ។ បើទោះបីជាមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ចែងថាៈ *"ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ"* ក៏ដោយ ក៏នៅតែត្រូវស្វែងរកតុល្យភាពមួយដែលមិនអាចជៀស បាន រវាងការប្រកួតប្រជែងសិទ្ធិទាំងនេះ។ សិទ្ធិបុគ្គលភាពឯកជននានា ត្រូវតែបានគោរពផងដែរ មានការចោទប្រកាន់មួយចំនួន ត្រូវបានធ្វើឡើងដោយផ្អែកទៅលើព័ត៌មានតាមអនឡាញ ឬកាសន្ទនាតាមទូរស័ព្ទ ដែលនីត្យានុកូលភាពរបស់វាត្រូវការបញ្ជាក់ឲ្យមានភាពច្បាស់លាស់បន្ថែមទៀត។ ខ្ញុំសូមបញ្ជាក់បន្ថែមទៀតនូវអនុសាសន៍របស់ខ្ញុំដែលថា រដ្ឋាភិបាលត្រូតពិនិត្យឡើងវិញនូវបទប្បញ្ញត្តិសំខាន់ៗនៃក្រមព្រហ្មទណ្ឌ (រួមទាំងបទល្មើសបរិហារកេរ្តិ៍ជាសាធារណៈ និងជេរប្រមាថ) និងការអនុវត្តច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានានូវភាពស្របគ្នាពេញលេញជាមួយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា ក៏ដូចជាតួអង្គសំខាន់ៗដទៃទៀត បានផ្សព្វផ្សាយអំពីការវិភាគទៅលើភាពស្របគ្នានេះ ហើយខ្ញុំក៏កំពុងត្រៀមខ្លួនក្នុងការជួយជ្រោមជ្រែងផងដែរ។

នៅក្នុងរបាយការណ៍របស់ខ្ញុំ ខ្ញុំកត់សម្គាល់ឃើញ ត្រង់កថាខ័ណ្ឌទី ៨ ថា ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងផ្សះផ្សារពិតប្រាកដពីគណៈបក្សនយោបាយធំទាំងពីរ ដើម្បីបង្កើតវប្បធម៌សន្ទនាឡើងវិញ ក្នុងបរិយាកាសគោរពគ្នាទៅវិញទៅមកទេនោះ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អាចនឹងមានភាពកាន់តែធ្ងន់ធ្ងរឡើងក្នុងរយៈពេលពេលប៉ុន្មានខែទៀតខាងមុខនេះ។ មានស្ថានភាពសិទ្ធិមនុស្សកាន់តែធ្ងន់ធ្ងរ បានកើតឡើងយ៉ាងជាក់ស្តែង។ នៅអំឡុងប៉ុន្មានសប្តាហ៍កន្លងទៅនេះ មានការធ្វើសមយុទ្ធយោធានៅក្នុងរាជធានីភ្នំពេញ ដែលនាំមកនូវការបំផិតបំភ័យ និងការភ័យខ្លាច នៅពេលកំពុងមានការចាប់ខ្លួន និងធ្វើការចោទប្រកាន់ជាច្រើនករណី ដែលនាំឲ្យមានការរួមតូចនូវកិច្ចពិភាក្សាខាងនយោបាយស្របច្បាប់ និងគំនិតផ្ទុយគ្នា ការធ្វើពហិការជាទៀងទាត់មិនចូលប្រជុំសភា និងព្រឹទ្ធភាពីគណៈបក្សសង្គ្រោះជាតិ ព្រមទាំងការអំពាវនាវឲ្យមានការធ្វើមហាបាតុកម្ម។ តំណាងរាស្ត្រគណៈបក្សសង្គ្រោះជាតិចំនួន ១៤ រូប បច្ចុប្បន្នកំពុងត្រូវបានចោទប្រកាន់ ចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវបានផ្តន្ទាទោសពីបទប្រព្រឹត្តបទល្មើសផ្សេងៗ។ ថ្វីបើខ្ញុំបានដឹងថាមានវិធានការ ត្រូវបានចាត់ឲ្យមានឡើងប្រឆាំងនឹងសមាជិកគណៈបក្សប្រជាជនកម្ពុជា មួយចំនួនក៏ដោយ ក៏អានុភាពនៃការចាត់វិធានការបែបនេះ មានលក្ខណៈធ្ងន់ធ្ងរច្រើនជាងចំពោះគណៈបក្សប្រឆាំង ទាក់ទងនឹងចំនួនជនត្រូវចោទ និងភាពធ្ងន់ធ្ងរនៃការចោទប្រកាន់ ព្រមទាំងការកាត់ទោស។ អ្នកដឹកនាំ ១ រូប

របស់គណៈបក្សសង្គ្រោះជាតិ កំពុងនិរទេសខ្លួនដោយខ្លួនឯង រីឯអ្នកដឹកនាំ ១ រូបទៀត កំពុងស្ថិតនៅក្នុងទីស្នាក់ការគណៈបក្សសង្គ្រោះជាតិ ដើម្បីគេចឲ្យផុតពីការចាប់ខ្លួន លោកត្រូវបានកាត់ទោសកំបាំងមុខ នៅអំឡុងដើមខែនេះ ពីបទបដិសេធមិនព្រមចូលខ្លួននៅចំពោះមុខតុលាការ។ ការផ្តន្ទាទោសខាងព្រហ្មទណ្ឌនេះធ្វើឲ្យបាត់បង់មុខតំណែងខាងនយោបាយ ហេតុដូច្នេះ មិនអាចមើលស្រាលនូវភាពធ្ងន់ធ្ងរនៃស្ថានការណ៍នេះបានឡើយ។ បន្ថែមទៅលើអំពើហិង្សា ដែលត្រូវបានរាយការណ៍ក្នុងកថាខ័ណ្ឌទី ៧ នៃរបាយការណ៍របស់ខ្ញុំនៅក្នុងខែ កក្កដា ឆ្នាំនេះ លោក កែម ឡី ជាសកម្មជននយោបាយដ៏លេចធ្លោ ១ រូប ត្រូវបានគេបាញ់សម្លាប់នៅក្នុងរាជធានីភ្នំពេញ។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្នជនសង្ស័យ ១ រូបត្រូវបានចាប់ខ្លួន ហើយមានសំណួរជាច្រើនមិនទាន់អាចឆ្លើយបានពាក់ព័ន្ធនឹងឧបទ្ទវហេតុទាំងនេះនៅឡើយទេ។

មានការបង្កហេតុ និងការប្រឆាំងនឹងការបង្កហេតុ ដែលបានលើកឡើងក្នុងទ្រឹស្តីបទរបស់គណៈបក្សនយោបាយធំទាំងពីរ ទោះជាយ៉ាងណា ក្នុងអំឡុងពេលនៃការបោះឆ្នោតចុងក្រោយ ប្រជាពលរដ្ឋកម្ពុជាបានសម្តែងការគាំទ្រចំពោះគណៈបក្សទាំងពីរ ហើយដូច្នេះ ពួកគេត្រូវបំពេញការងាររួមគ្នាដើម្បីបម្រើដល់ប្រជាពលរដ្ឋដែលបានបោះឆ្នោតឲ្យពួកគេ។ នៅឆ្នាំ ២០១៤ "វប្បធម៌សន្ទនា" គឺជាឧបករណ៍ដែលត្រូវបានជ្រើសរើសដោយគណៈបក្សនយោបាយទាំងពីរ។ វប្បធម៌សន្ទនានេះ មិនត្រូវបានប្រើប្រាស់ទៀតទេនាថ្ងៃនេះ ក៏ប៉ុន្តែ ការផ្អាកជាបណ្តោះអាសន្ននូវការបំពានគ្នាត្រូវបានគេមើលឃើញនាពេលថ្មីៗនេះ (ខ្ញុំមានសេចក្តីសោមនស្សដែលបានទទួលព័ត៌មានថា សម្តេចតេជោនាយករដ្ឋមន្ត្រី ទើបតែបានអំពាវនាវឲ្យមានការ "បញ្ឈប់ការវាយប្រហារគ្នាទៅវិញទៅមក" ជាបណ្តោះអាសន្ន នៅក្នុងអវិភាពផ្ទៃកនយោបាយ) ផ្តល់នូវកាលានុវត្តភាពក្នុងការបន្តឡើងវិញនូវវប្បធម៌សន្ទនានេះ តាមរយៈការដោះស្រាយបញ្ហាមូលដ្ឋានគ្រឹះនានា។ នៅក្នុងកថាខ័ណ្ឌទី៥៥ នៃរបាយការណ៍របស់ខ្ញុំ ខ្ញុំបានកត់សម្គាល់ថា ប្រសិនបើស្ថានភាពនយោបាយមិនមានស្ថេរភាពនៅក្នុងបរិយាកាសនៃការគោរពសិទ្ធិមនុស្សនោះទេ ភាពជឿជាក់នៃការបោះឆ្នោតដែលនឹងមកដល់នាពេលខាងមុខ អាចនឹងមានភាពកាន់តែធ្ងន់ធ្ងរ។

លោកប្រធាន ឯកឧត្តម លោកជំទាវ ជាទីគោរព សេចក្តីប្រាថ្នាចង់បាន ដែលមានបញ្ជាក់ក្នុងបុព្វកថានៃកិច្ចព្រមព្រៀងទីក្រុងបារីស កាលពីម្ភៃប្រាំឆ្នាំមុន *"ក្នុងការជំរុញបង្រួបបង្រួមជាតិ និងធានាឲ្យប្រជាជនកម្ពុជាប្រើប្រាស់សិទ្ធិស្វ័យសម្រេចតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ"* នៅតែមានទំនាក់ទំនងគ្នានាពេលបច្ចុប្បន្ននេះ។

សូមអរគុណ។